# ដំណឹងជ្រើសរើសសិក្ខាកាមចូលរួមសិក្ខាសាលាចតុស្តីពី «ការសរសេរដំឡើងស្នាដៃរបាំ»

សិល្បៈខ្មែរអមតៈ

**ព័ត៌មានទូទៅអំពីសិក្ខាសាលាចតុស្តីពី «ការសរសេរដំឡើងស្នាដៃរបាំ »**

សិក្ខាសាលានេះជាផ្នែកមួយនៃ**គម្រោងចតុ**ដែលផ្តល់មូលនិធិដោយវិទ្យាស្ថានបារាំងនៅកម្ពុជា ដើម្បីលើកស្ទួយឧស្សាហកម្មច្នៃប្រតិដ្ឋនិងវប្បធម៌នៅកម្ពុជា។ ដោយផ្តោតជាពិសេសលើការសរសេរ គម្រោងនេះមានគោលបំណងផ្តល់ឱកាសដល់អ្នកមានទេពកោសល្យជាជនជាតិកម្ពុជាដែលទើបប្រឡូកនៅក្នុងវិស័យ៤ (ភាពយន្ត សៀវភៅ របាំនិងតន្ត្រី) ដោយសហការជាដៃគូជាមួយក្រុមហ៊ុនផលិតកម្មភាពយន្ត Anti-Archive, អង្គការស៊ីប៉ា , អង្គការសិល្បៈខ្មែរអមតៈ និងផលិតកម្មកងចក្រភីកឈ័រ។

គំនិតផ្តួចផ្តើមនេះនាំមកជូននូវសិក្ខាសាលាចំនួន២ ៖

**សិក្ខាសាលាទី១ ៖** Masterclass **សម្រាប់អ្នកដំឡើងក្រឡារបាំរៀមច្បង (ថ្ងៃ១១-១៦ កុម្ភៈ ២០២៥)**
គោលបំណងនៃសិក្ខាសាលាទី១នេះគឺដើម្បីពង្រឹងសមត្ថភាពសរសេរដំឡើងរបាំរបស់អ្នកដំឡើងក្រឡារាំរៀមច្បង តាមរយៈការពង្រឹងចំណេះដឹងមូលដ្ឋានគ្រឹះរបស់ពួកគេនិងតាមរយៈការផ្តល់បទពិសោធន៍ថ្មីៗ។ អ្នកចូលរួមនឹងត្រូវបានជ្រើសរើសជាជំនួយការគ្រូបណ្តុះបណ្តាលនៅក្នុងសិក្ខាសាលាវគ្គ២។ អ្នកចូលរួមដែលត្រូវបានជ្រើសរើសនឹងទទួលបានប្រាក់ឧបត្ថម្ភសមរម្យផងដែរ។

នៅក្នុងវគ្គ១នេះ យើងនឹងជ្រើសរើសអ្នកចូលរួមចំនួន**<u>រហូតដល់៥រូប</u>** ដែលត្រូវចូលរួម **Masterclass** ដឹកនាំដោយ**លោកហ្វូអាដ់ ប៊ូស៊ូហ្វ** (Fouad Boussouf) នាយកនៃមជ្ឈមណ្ឌល Le Phare CCN Du Havre និងជាគ្រូរបាំសហសម័យដ៏ល្បីនៅប្រទេសបារាំង។
កម្មវិធីផ្តោតលើការដុះខាត់ជំនាញសរសេរដំឡើងស្នាដៃរបាំរបស់អ្នកចូលរួម និងពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការបង្កើតគំនិត និងបង្កើតស្នាដៃរបាំប្រកបដោយភាពច្នៃប្រតិដ្ឋ។ ចំពោះព័ត៌មានអំពីគ្រូបណ្តុះបណ្តាល និងមជ្ឈមណ្ឌល **Le Phare CCN Du Havre** សូមចុចលើ<u>តំណភ្ជាប់</u>នេះ។

**Masterclass** មានរយៈពេលសរុប៣៦ម៉ោង ដោយក្នុង១ថ្ងៃរៀន៦ម៉ោង៖

- ពេលព្រឹក ៖ ៩-១២ថ្ងៃត្រង់
- ពេលរសៀល ៖ ១:៣០-៤:៣០រសៀល

បន្ថែមពីលើសកម្មភាពនៅក្នុងថ្នាក់ អ្នកចូលរួមអាចនឹងតម្រូវឱ្យអានឯកសារឬមើលវីដេអូមុន និងក្នុងពេលសិក្សា។ **Masterclass** នឹងប្រព្រឹត្តទៅជាភាសាអង់គ្លេស និងមានបកប្រែជាភាសាខ្មែរ។

**សិក្ខាសាលាទី២ ៖ បណ្តុះបណ្តាលអ្នកដំឡើងក្បាច់របាំវ័យក្មេងរឹមានបទពិសោធស្តួចស្តើង (២១-២៣ខែមីនា និង២៨-៣០ខែមីនា ឆ្នាំ២០២៥)**

ដំណាក់កាលទី២មានគោលបំណងផ្តល់ចំណេះដឹងមូលដ្ឋានគ្រឹះនៃការសរសេរដំឡើងសម្រាប់អ្នកដំឡើងក្បាច់វ័យក្មេងចំនួន១២នាក់។ អ្នកចូលរួមទាំង១២នាក់នេះដែលនឹងត្រូវជ្រើសរើសតាមរយៈការដាក់ពាក្យនឹងចូលរួមការហ្វឹកហាត់ដ៏តឹងរ៉ឹង ដឹកនាំដោយអ្នកស្រីអែមម៉ានុយអែល ភួន ([Emmanuèle Phuon]) គ្រូរបាំសហសម័យជនជាតិបារាំង។ ព័ត៌មានលម្អិតអំពីការដាក់ពាក្យចូលរួមសិក្ខាសាលាទី២នេះនឹងត្រូវផ្សព្វផ្សាយក្នុងការប្រកាសមួយផ្សេងទៀតនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥។

**លក្ខខណ្ឌនៃការជ្រើសរើសបេក្ខជនសម្រាប់សិក្ខាសាលាទី១**

បេក្ខជនអាចដាក់ពាក្យក្នុងនាមខ្លួនឯងផ្ទាល់ឬក្នុងនាមស្ថាប័នដែលខ្លួនធ្វើការ។
បេក្ខជនត្រូវមាន ៖

- បទពិសោធន៍យ៉ាងតិច៧ឆ្នាំក្នុងនាមជាអ្នកដំឡើងស្នាដៃរបាំ ដោយមិនរាប់បញ្ចូលរយៈពេលដែលបេក្ខជនបានសិក្សានៅសាលានោះឡើយ។
- មានភស្តុតាងបញ្ជាក់អំពីការបង្កើតនិងការបង្ហាញស្នាដៃថ្មី អាចជាការងារជាក្រុមឬម្នាក់ឯង នៅក្នុងស្រុក នៅថ្នាក់តំបន់ឬថ្នាក់អន្តរជាតិ។
- មានសកម្មភាពបច្ចុប្បន្ននៅក្នុងវិស័យរបាំសហសម័យនិងការដំឡើងស្នាដៃរបាំ ជាលក្ខណៈផ្ទាល់ខ្លួនឬជាមួយស្ថាប័ន។
- ផ្ញើគំរូស្នាដៃចំនួន៣ អាចជាការងារជាក្រុមឬម្នាក់ឯង។ អាចជាវីដេអូនិង/ឬរូបថត ដោយមានការពិពណ៌នាលម្អិត កាតាឡុកនៅក្នុងវិបសាយ។ល។
- ជនជាតិខ្មែរ ឬមាន K-Visa។
- រស់នៅប្រទេសកម្ពុជាអំឡុងពេលដាក់ពាក្យនិងអំឡុងពេលសិក្ខាសាលា។
- មានពេលវេលាគ្រប់គ្រាន់ចូលរួមកម្មវិធីទាំងមូល និងចូលរួមសិក្ខាសាលាទាំងអស់យ៉ាងសកម្ម។
- មានឆន្ទៈចង់ចែករំលែកគំនិត និងធ្វើជាជំនួយការគ្រូបណ្តុះបណ្តាលអ្នកដំឡើងរបាំ នៅដំណាក់កាលទី២ (ព័ត៌មានលម្អិតអំពីទំនួលខុសត្រូវផ្សេងៗនឹងត្រូវ ជជែកពិភាក្សាជាមួយគ្រូបណ្តុះបណ្តាលបង្គោល)។

## ការដាក់ពាក្យ

ថ្ងៃផុតកំណត់ការដាក់ពាក្យគឺនៅថ្ងៃទី**២៨ ខែមករា ឆ្នាំ២០២៥**។

បេក្ខជនអាចយកឯកសារមកដាក់ផ្ទាល់នៅទីស្នាក់ការរបស់អង្គការសិល្បៈខ្មែរអមតៈ (ផ្ទះ១៣E ផ្លូវ៨៣០ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ) ឬតាមរយៈអ៊ីម៉ែល ៖ tola@cambodianlivingarts.org

ឯកសារដែលបេក្ខជនត្រូវភ្ជាប់មកជាមួយរួមមាន ៖

- ទម្រង់បែបបទបេក្ខភាពដែលបំពេញរួច
- ប្រវត្តិរូប ដោយសង្ខេបពីប្រវត្តិសិក្សានិងប្រវត្តិការងារដែលពាក់ព័ន្ធ
- គំរូស្នាដៃកន្លងមកចំនួន៣

ការដាក់ពាក្យអាចបំពេញជាភាសាខ្មែរឬអង់គ្លេស ទៅតាមភាពងាយស្រួលរបស់អ្នក។ បន្ថែមពីលើការសរសេរបំពេញទម្រង់បែបបទ បេក្ខជនអាចដាក់ពាក្យជាវីដេអូឬជាសំឡេង សម្រាប់សំណួរខ្លះឬគ្រប់សំណួរ។ ចំពោះវីដេអូគឺមិនត្រូវលើសពី១០នាទី ហើយបេក្ខជនត្រូវប្រាកដខ្លួនឯងថាបានលើកឡើងគ្រប់ចំណុចដែលពាក់ព័ន្ធ។

## ដំណើរការជ្រើសរើស

ការជ្រើសរើសនឹងត្រូវធ្វើឡើងដោយគណៈកម្មការឯករាជ្យមួយក្រុម។
បេក្ខភាពដែលជាប់ឈ្មោះជ្រើសរើសនឹងទទួលបានដំណឹងនៅ**ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៥**។

បេក្ខភាពដែលមិនត្រូវបានជ្រើសរើសនឹងទទួលបានដំណឹងនៅ**ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥**។ បេក្ខជនក៏នឹងទទួលបានមតិណែនាំផងដែរ។ បើមានចម្ងល់ផ្សេងៗ សូមទាក់ទង ៖ tola@cambodianlivingarts.org ឬ តេឡេក្រាម +៨៥៥ ៧៧ ៥៥ ៨៥ ៨៥។

**កម្មវិធីនេះអាចដំណើរការទៅបានដោយសារការឧបត្ថម្ភគាំទ្រពីវិទ្យាស្ថានបារាំងនៅកម្ពុជា។**